# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៤១ សហវ.ថហ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០២

## ប្រកាសអន្តរក្រសួង

### ស្តីពី

### ការតែងតាំងភ្នាក់ងារបើកផ្តល់ សំរាប់បើកប្រាក់បៀវត្សរ៍ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ នៅ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

=====

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ ន.ស.រ.ក.ត១១៩៨/៧២ ចុះថ្ងៃ ទី ៣០ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ០១ ន.ស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស.រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃ ទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើ ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យនៃសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.មប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

## សំ  រេ ច

ប្រការ១ : ប្រាក់បៀវត្សរ៍មន្ត្រីរាជការ នៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ត្រូវបើកផ្តល់តាមរយៈ " ភ្នាក់ងារបើកផ្តល់ " ។

ប្រការ២ : លោក អ៊ុម ហេន ត្រូវបានតែងតាំងជា ភ្នាក់ងារបើកផ្តល់ នៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជំនួសលោក គៀត សត្ថារ៉ាឌី ដែលត្រូវទៅបំពេញការងារនៅស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋបារាំង និងលោក ម៉ែន ខណ្ណា ជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ៣ : លោក អ៊ុម ហេន និង លោក ម៉ែន ខណ្ណា ត្រូវបានអនុញ្ញាតិអោយបើកគណនីប្រាក់បញ្ញើ នៅ រតនាគារជាតិដើម្បី ទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ

ប្រការ៤ : បែបបទនៃការអនុវត្តន៍ បើកផ្តល់បៀវត្ស និង ត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ

ប្រការ៥ : ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និង មូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ

ប្រការ៦ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនិងប្រកាសនេះត្រូវទុកជានិរាករណ៍

ប្រការ៧ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ពន្ធ័ទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិព្រមទាំងលោក អ៊ុម ហេន និង លោក ម៉ែន ខណ្ណា ត្រូវទទួលបន្ទុកអនុវត្តន៍តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ហោ ណាំហុង

កន្លែងទទួល :

- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៧ " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ